ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ១១៥/១៥ ក.អ.ជ.ប្រក

ថ្ងៃចន្ទ ១កើត ខែជេស្ឋ ឆ្នាំមមែ ព.ស. ២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែឧសភា គ.ស. ២០១៥

## ប្រកាស

## ស្តីពីការតែងតាំងអង្គភាពអនុវត្តន៍គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ១៥៧/១៤ ក.អ.ជ.ប្រក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ របស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងឥណទានជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមការងារចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** តែងតាំងអង្គភាពអនុវត្តន៍គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ដែលមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១. លោក **សេង ជាសុខ** | ប្រធានអង្គភាព |
| ២. លោក **លី សុផល** | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣. កញ្ញា **ពេជ្រ រដ្ឋា** | ភ្នាក់ងារឥណទានប្រចាំស្រុកសន្ទុក |

**ប្រការ ២.-** អង្គភាពអនុវត្តន៍គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រតិបត្តិគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទប្រចាំខេត្តកំពង់ធំ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងចីរភាព ដោយផ្អែកលើគោលនយោបាយ នីតិវិធី និងគោលការណ៍ ជាធរមាន ដែលកំណត់ដោយក្រសួងអភិវឌ្ឍន៍ជនបទ។

**ប្រការ ៣.-** អង្គភាពអនុវត្តន៍គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការអាជីវកម្មប្រចាំឆ្នាំរបស់គម្រោងឱ្យមានប្រសិទ្ធភាពខ្ពស់
- ផ្តល់សេវាឥណទានក្នុងអត្រាការប្រាក់ តាមការកំណត់របស់គណៈកម្មការគ្រប់គ្រងគម្រោងឥណទានជនបទ
- ប្រមូលប្រាក់ដើម និងការប្រាក់មកវិញឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា
- គ្រប់គ្រងហិរញ្ញវត្ថុ ឥណទាន និងសារពើភ័ណ្ឌក្នុងតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់
- រៀបចំផែនការបណ្តុះបណ្តាលដល់មន្ត្រី និងភ្នាក់ងារឥណទាន
- រៀបចំផែនការយុទ្ធសាស្ត្រ និងការប្រកួតប្រជែងទីផ្សារ
- សហប្រតិបត្តិការ និងស្វែងរកដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងស្ថាប័នផ្សេងៗ ដើម្បីពង្រីកទុនឥណទាន និងតំបន់ប្រតិបត្តិការ ។

**ប្រការ ៤.-** រាល់សេចក្តីសម្រេចទាំងឡាយ ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-** នាយកខុទ្ទកាល័យ គណៈកម្មការគ្រប់គ្រងគម្រោងឥណទានជនបទ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ និងសាមីជនដែលរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ជា សុផារ៉ា

<u>កន្លែងទទួល÷</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- សាលាខេត្តកំពង់ធំ
  *“ដើម្បីជូនជ្រាប”*
- ដូចប្រការ៥
  *“ដើម្បីអនុវត្ត”*
- ឯកសារ-កាលប្បវត្តិ